AMRO
ASEAN +3 MACROECONOMIC RESEARCH OFFICE

10 Shenton Way
#15-08, MAS Building
Singapore 079117
T: +65 6323 9844
F: +65 6223 8187
www.amro-asia.org

# របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចតំបន់អាស៊ានបូកបី ឆ្នាំ ២០១៨

# ASEAN+3 Regional Economic Outlook (AREO) 2018

## ខ្លឹមសារគន្លឹះ

## ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

១. កំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ានបូកបីត្រូវបានព្យាករថា នឹងកើនឡើងក្នុងអត្រា ៥,៤% ក្នុងឆ្នាំ ២០១៨ ដែលទ្រទ្រង់ដោយកំណើននៃតម្រូវការក្នុងស្រុក និងការនាំចេញ ខណៈដែលអតិផរណាមានស្ថិរភាព។ សេដ្ឋកិច្ចចិន និងជប៉ុន ដែលជាសេដ្ឋកិច្ចធំជាងគេពីរក្នុងតំបន់ មានកំណើនរឹងមាំ។

២. យោងតាមការវិភាគរបស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចតំបន់អាស៊ានបូកបី (AMRO), ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសភាគច្រើនក្នុងតំបន់ស្ថិតក្នុងវដ្តកំណើនសេដ្ឋកិច្ចកម្រិតកណ្តាល (mid-business cycle) ដែលកំណើនសេដ្ឋកិច្ចកំពុងងើបឡើង ជាមួយនឹងទិន្នផលសេដ្ឋកិច្ចខិតទៅជិតសូន្យ ខណៈដែលអតិផរណាដែលមានស្ថិរភាព។ ចំពោះវដ្តកំណើនឥណទានវិញ កំណើនឥណទាននៅក្នុងបណ្តាប្រទេសជាច្រើនក្នុងតំបន់ ត្រូវបានសង្កេតឃើញថាស្ថិតក្នុងល្បឿនយឺតជាងមុន បន្ទាប់ពីមានកំណើនខ្ពស់លើសពីកំណើននិន្នាការ (above-trend growth) ដោយសារអជ្ញាធរនៃប្រទេសនីមួយៗក្នុងតំបន់បានអនុវត្តសកម្មភាពគោលនយោបាយបុរេសកម្ម។

៣. ភាពល្អប្រសើរឡើងនៃតម្រូវការពីតំបន់ខាងក្រៅ (external demand) បានជួយដល់តំបន់អាស៊ានបូកបី ក្នុងការបង្កើនសមត្ថភាពទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅដែលអាចកើតមានឡើងនាពេលអនាគត។ អត្រាប្តូរប្រាក់ក្នុងតំបន់អាស៊ានបូកបី ដែលប្រកបដោយភាពកាន់តែបត់បែនជាងមុនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយការប៉ះទង្គិចពីខាងក្រៅ។

៤. តាមរយៈផែនទីហានិភ័យសកលរបស់ AMRO (AMRO’s Global Risk Map) ដែលបានវិភាគលើលទ្ធភាព (likelihood) និងរយៈពេល (imminence) នៃហានិភ័យ តំបន់អាស៊ានបូកបីកំពុងជួបប្រទះនូវហានិភ័យរយៈពេលខ្លីចំនួនពីរ ពោលគឺការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុសកល ដែលមានសភាពលឿនជាងការរំពឹងទុក និងការកើនឡើង

នៃភាពតានតឹងពាណិជ្ជកម្មសកល។ ប្រសិនបើហានិភ័យនេះនឹងកើតឡើងមែន តំបន់អាស៊ានបូកបីនេះនឹងទទួលរង នូវឥទ្ធិពលអវិជ្ជមាន តាមរយៈលំហូរចេញនៃមូលធន, ការកើនឡើងនៃចំណាយលើការខ្ចី ព្រមទាំងតាមរយៈលំហូរពាណិជ្ជកម្ម និងវិនិយោគផងដែរ។

៥. ដើម្បីដោះស្រាយហានិភ័យទាំងនេះ និងរក្សាកំណើនសេដ្ឋកិច្ច អ្នករៀបចំគោលនយោបាយគួរបន្តកសាងគោលនយោបាយធំទូលាយ (policy space) ជាពិសេសគោលនយោបាយរូបិយវត្ថុ ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងការរឹតបន្តឹងហិរញ្ញវត្ថុសកលកាន់តែខ្លាំងនាពេលអនាគត។ គោលនយោបាយសារពើពន្ធអាចដើរតួនាទីកាន់តែសំខាន់ជាងមុនក្នុងការជំរុញកំណើន ប៉ុន្តែការប្រើប្រាស់គោលនយោបាយនេះតម្រូវឱ្យអ្នករៀបចំគោលនយោបាយគិតគូរពិចារណាឱ្យបានម៉ត់ចត់ដល់លំហថវិកា (fiscal space) និងវិធានសារពើពន្ធ (fiscal rules)។ ចំពោះវិស័យណា ដែលកំពុងប្រឈមនឹងការកើនឡើងនៃភាពងាយរងគ្រោះដោយសារកំណើនឥណទាននាពេលកន្លងមក ការរឹតបន្តឹងគោលនយោបាយប្រុងប្រយ័ត្នម៉ាក្រូសេដ្ឋកិច្ចអាចជួយរក្សាស្ថិរភាពហិរញ្ញវត្ថុបាន។

## ប្រធានបទស្នូលៈ ភាពធន់ និងកំណើនសេដ្ឋកិច្ចក្នុងពិភពលោកដែលពោរពេញដោយការវិវត្ត

៦. ប្រទេសនានាក្នុងតំបន់អាស៊ានបូកបីបានអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ (manufacturing for exports)" ក្នុងរយៈពេលពីរបីទសវត្សកន្លងមកនេះ ដែលការប្រកាន់ខ្ជាប់នូវយុទ្ធសាស្ត្រនេះបានជួយឱ្យតំបន់អាស៊ានបូកបីបង្កើតបាននូវជវភាពរបស់ខ្លួន ដើម្បីជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ ក៏ដូចជាបង្កើនផលិតភាព និងប្រាក់ឈ្នួល។

៧. យុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ" នេះ កំពុងតែប្រឈមនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធនៃខ្សែចង្វាក់តម្លៃសកលដែលកំពុងស្ថិតក្នុងស្ថានភាពទ្រឹង ស្របពេលដែលសមត្ថភាពផលិតភាពក្នុងស្រុក (domestic productive capacity) មានលក្ខណៈល្អប្រសើរជាងមុន ដែលអាចឱ្យប្រទេសនានាធ្វើការផលិត ជាជាងនាំចូលវត្ថុធាតុដើម។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ការកើនឡើងនៃតម្រូវការចុងក្រោយក្នុងតំបន់ (intra-regional final demand) ដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយស្រូបយកនូវការនាំចេញនៅក្នុងតំបន់បានច្រើនជាងមុន ព្រមទាំងអាចជួយទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅដែលបណ្តាលមកពីការគាំពារពាណិជ្ជកម្ម។

៨. បច្ចេកវិទ្យាត្រូវបានចាត់ទុកជាអាវុធមុខពីរ ដែលគំរាមកំហែងដល់ការអនុវត្តយុទ្ធសាស្ត្រ "ការផលិតដើម្បីនាំចេញ"។ ការប្រើប្រាស់បច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្ម (automation) នៅក្នុងវិស័យកម្មន្តសាល មានន័យថាវិស័យនេះនឹងមិន

បង្កើតឱកាសការងារបានច្រើនដូចកាលពីមុនទៀតនោះទេ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី បច្ចេកវិទ្យាបានជួយសម្រួលដល់វិស័យសេវាកម្ម ដែលអាចក្លាយជាក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចថ្មីមួយ និងបង្កើតឱកាសការងារផងដែរ។

៩. ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ តំបន់ទាំងមូលគួរពង្រឹងការតភ្ជាប់ និងសមាហរណកម្មក្នុងតំបន់ សម្រាប់បំពេញកំណើនតម្រូវការក្នុងតំបន់ ក៏ដូចជាពង្រឹងភាពធន់ក្នុងតំបន់ ដើម្បីទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ។ អនុសាសន៍គន្លឹះសម្រាប់ប្រទេសនីមួយៗក្នុងតំបន់ គឺការកសាងភាពធន់តាមរយៈការធ្វើពិពិធកម្មក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ច ដែលរួមមានតាមរយៈវិស័យសេវាកម្ម។

១០. ធនធានដ៏ច្រើនសន្ធឹកសន្ធាប់ និងភាពចម្រុះនៃការអភិវឌ្ឍក្នុងតំបន់អាស៊ានបូកបីទាំងមូល គឺជាប្រភពកម្លាំងដ៏រឹងមាំរបស់តំបន់នេះ។ គោលនយោបាយនានាគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងការតភ្ជាប់ តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ទាំងក្នុងស្រុក និងក្នុងតំបន់ ក៏ដូចជាការអនុវត្តគោលនយោបាយសម្រួលពាណិជ្ជកម្ម។ គោលនយោបាយដែលជួយជំរុញដល់ការអភិវឌ្ឍវិស័យសេវាកម្ម និងធនធានមនុស្ស រួមមានសេរីភាវូបនីយកម្មនៃវិស័យសេវាកម្ម និងការប្រើប្រាស់ធនធានមនុស្សដែលមានស្រាប់ក្នុងតំបន់អាស៊ានបូកបី តាមរយៈការអនុវត្តគោលនយោបាយដែលគាំទ្រដល់ទេសន្តប្រវេសន៍។

*បញ្ជាក់៖ ខ្លឹមសារគន្លឹះជាភាសាខ្មែរនេះ ត្រូវបានប្រែសម្រួលចេញពីខ្លឹមសារគន្លឹះដើមជាភាសាអង់គ្លេស ដែលអាចទាញយកបានតាមរយៈតំណភ្ជាប់នេះ (http://www.amro-asia.org/asean3-regional-economic-outlook-2018-key-messages)។ ខ្លឹមសារគន្លឹះនេះត្រូវបានប្រែសម្រួលយ៉ាងប្រុងប្រយ័ត្នបំផុត ដើម្បីធានាភាពត្រឹមត្រូវស្របតាមសំណេរដើម ប៉ុន្តែប្រសិនបើមានកំហុសឆ្គង ឬខ្វះចន្លោះត្រង់ចំណុចណាមួយនោះ ខ្លឹមសារគន្លឹះជាភាសាអង់គ្លេសត្រូវបានកំណត់យកជាគោល។*